ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ០៦ សប្តាហ៍ទី ៣ ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

p

ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកស្រី **ហេង គឹមហឿន** ៦០៣

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ លោកស្រី អស់លោក និង សប្បុរសជន ចំនួន ៩១ រូប ៦០៤

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ លោកស្រី អស់លោក និង សប្បុរសជន ចំនួន ៤៣ រូប ៦០៦

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោកឧកញ៉ា **សា ថោង** ៦០៧

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០០៩ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ចំនួន ០១ រូប ៦០៨

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១០ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ង៉ាន់ ឡាច** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦០៩

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ នាយទាហាន នៃ សាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន ០២ រូប ៦១០

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និង សប្បុរសជន ចំនួន ០៨ រូប ៦១១

០២.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ១២ រូប ៦១២

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សាចិន ចំនួន ០៤ រូប ៦១៣

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាល និង នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ១០៧ រូប ៦១៤

០២-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០៣ រូប ៦១៩

០៣-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៧ ស្តីពី ការតែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៤ ចំនួន ០៣ រូប ៦២០

០៣-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៨ ស្តីពី ការតែងតាំងមន្ត្រីរាជការឧត្តម ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ១៧ រូប ៦២១

០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០១៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **អារាស៊ីគូវ៉ា អាលីហ្សា** (HARASIKOVA ALISA) ជនជាតិរុស្ស៊ី សញ្ជាតិអ៊ុយបេគីស្ថាន កើតនៅតំបន់តាស្កេន ប្រទេសអ៊ុយបេគីស្ថាន ដោយប្តូរឈ្មោះជា **សុខ អាលីហ្សា** (SOK ALISA) ៦២៤

០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **មីខៃឡូវ ស្តានីស្លាវ** (MIKHAILOV STANISLAV) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតនៅទីក្រុងឆេលយ៉ាប៊ីន សហព័ន្ធរុស្ស៊ី ដោយប្តូរឈ្មោះជា **រ៉ូស ស្ទីវិន** (ROSS STIVEN) ៦២៥

០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **រោមស៊ីន មីខាអ៊ីល** (RYUMSHIN MIKHAIL) ជនជាតិ រុស្ស៊ី សញ្ជាតិរុស្ស៊ី កើតនៅទីក្រុងអាល់ហ្គាបេដ សហព័ន្ធរុស្ស៊ី ៦២៦

០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អូ មូនតៃ** (OH MOON TAI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **អូរ គីមសាន្ត** (OH KIMSAN) ៦២៧

០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា នាយ នាយរងនគរបាលជាតិ និង សប្បុរសជន ចំនួន ១៣ រូប ៦២៨

p

គ

០៤.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោកជាមន្ត្រីរាជការ និង សប្បុរសជន ចំនួន ៣២ រូប ៦២៩

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

១១.០១.២០១៣ - អនុក្រឹត្យលេខ ១២ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៩២០,១៧១៧ ហិកតា ស្រុកបរកែវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៧ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង ការផ្ដល់សិទ្ធិលើក្បាលដី ៦៣០

១៤.០១.២០១៣ - អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៥១,៦៧៥៧ ហិកតា នៅក្នុងស្រុកអង្គរជ័យ ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ ៦៣៣

១៤.០១.២០១៣ - អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៧៩០,៤៣៩២ ហិកតា នៅក្នុងស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៦

១៤.០១.២០១៣ - អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្ដីពី ការកាត់ដីទំហំសរុប ៤.៩៣៨ ហិកតា នៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី ចេញពីដែនជម្រកសត្វព្រៃ ស្នួល និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន និង សុំប្រទានកម្ម ជំនួសសម្បទានសេដ្ឋកិច្ច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៩៤ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៩

១៤.០១.២០១៣ - អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្ដីពី ការកាត់ដីទំហំសរុប ១.៧៨៨ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ដែលក្នុងនោះកាត់ ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានរបស់ក្រុមហ៊ុនយូរីសាគរ និង ពីព្រៃសម្បទានព្រៃឫស្សី របស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៦៧ គ្រួសារ ៦៤២

១៤-០១-២០១៣ - អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.៩៣៩,១៥ ហិកតា នៅស្រុកថ្មបាំង ខេត្តកោះកុង ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៤៥

១៤-០១-២០១៣ - អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.២៥៥,២៦៤៤ ហិកតា នៅក្នុងស្រុកទឹកឈូ ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៤៨

១៣-១១-២០១២- អនុក្រឹត្យលេខ **២៤០៩** ដល់អនុក្រឹត្យលេខ **២៤៣៧** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៥១

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៣-១២-២០១២- ប្រកាសលេខ ១២១៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាកាយ៉ាម៉ា (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៨០

១៤-១២-២០១២ - ប្រកាសលេខ ១២១៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាយនើសធី អ៊ីភែរិល (ខេមបូឌា) ខមភេនី លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៨៤

១៤-១២-២០១២ - ប្រកាសលេខ ១២១៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ អិម អិម ប្លាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៨៨

១៤-១២-២០១២ - ប្រកាសលេខ ១២១៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ អេន ជេ (ខេមបូឌា) បង្កើតរោងចក្រ ផលិតកង់ ៦៩២

២០-១២-២០១២ - ប្រកាសលេខ ១២៤២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៩៦

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-៨-២០១១ - លិខិតបញ្ជាក់លេខ ៤៥៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាណាសាន់ ខ្មែរ សែសស៍ ៧០០

០៣-៨-២០១១ - លិខិតបញ្ជាក់លេខ ៤៦០៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាហ្វ្រីយ៉ា (ខេមបូឌា) ៧០២

០៣-៨-២០១១ - លិខិតបញ្ជាក់លេខ ៤៦១៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ធី អេច ឌី ខនស្រ្តាក់សិន ៧០៤

p

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រេន្ត គ្លូបល ប៊ីហ្សិនេស ស៊ីទីស** ៧០៦

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦២៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេដ ខែរហោស៍** ៧០៨

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦២៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាន តុខ ត្រេឌីង ខូ អិលធីឌី** ៧១០

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦៣៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង ឃុន ហ្វីដ ប្រដាក់ អេនធើប្រាយ** ៧១២

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦៣៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេចប៊ីធី គ្លូបល ត្រេឌីង** ៧១៤

០៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ **សាខា ធនាគារ អ៊ិនដាសស្ទ្រៀល អេន ខមមើសល ប៊ែង អហ្វ ឆាយណា លីមីធីត** ហៅ **ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ** ៧១៦

០៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ព្រីមែរ ជី ខេ** ៧១៧

០៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៦៤៤ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ឡូវ៉ង់ អ៊ីមផត អិចផត** ៧១៩

p

ព្រះរាជក្រឹត្យ

ស/រកត/០១១៣/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

ចំពោះ

លោកស្រី ហេង គឹមហៀង

ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួម
ជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង
ចូលរួមចំណែកជួយសាងសង់អគារភាគបាទក្រហមខេត្ត នៅខេត្តព្រៃវែង ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាស់ - ១៣០១.០០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣

លេខ: ០៥ ច.ល
បានឃើញថាចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ លោកស្រី អស់លោក និងសប្បុរសជនបានខិតខំយកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ចរបស់ខ្លួនរួមចំណែកកសាង និងអភិវឌ្ឍគ្រប់វិស័យក្នុងខេត្តបាត់ដំបង

នូវ

ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-លោកជំទាវ ម៉ម សម៉ើយ
២-លោកឧត្តមសេនីយ៍ឯក យ៉ាល់ ពិសិដ្ឋ
៣-លោកវរៈសេនីយ៍ឯក អ៊ឹម មុន្នីរត្ន
៤-លោកវរៈសេនីយ៍ឯក លី គុណហួរ
៥-លោកវរៈសេនីយ៍ទោ អ៊ុក ស៊ីថន
៦-លោកអនុសេនីយ៍ឯក សួង ចំរើន

ខ. គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនិនាថ្យ កុសុមៈ នារីរត្ន ថ្នាក់ មហាសិរីវឌ្ឍន៍ :

១-លោកវរៈសេនីយ៍ទោ ស្រេង សុខា
២-លោក គ្រឿង បញ្ញារិទ្ធិ
៣-លោក ម៉ក់ ម៉ុន្នា
៤-លោក សាន្ត សម្បត្តិ

គ. គ្រឿងឥស្សរិយយស ថ្នាក់សេនាជ័យសិទ្ធ :

១-ឯកឧតម ឧត្តមសេនីយ៍ឯក សុខ លីហួត
២-លោកឧត្តមសេនីយ៍ទោ ឡាយ ចិសោ
៣-លោកឧត្តមសេនីយ៍ទោ កើត ប៊ុលីន
៤-លោកឧត្តមសេនីយ៍ទោ អ៊ឹម ពុធនិធា
៥- លោកឧត្តមសេនីយ៍ទោ គុន សុផល
៦-លោកឧត្តមសេនីយ៍ទោ សុត ថុល
៧-លោកឧត្តមសេនីយ៍ត្រី សំ ស៊ុយ៉ាន
៨-លោកឧត្តមសេនីយ៍ត្រី អ៊ុង សាវ៉ាន់
៩-លោកឧត្តមសេនីយ៍ត្រី អ៊ី តារា
១០-លោកឧត្តមសេនីយ៍ត្រី ម៉ុល ផាន់ណា
១១-លោកវរៈសេនីយ៍ឯក សោម សោភ័ណ
១២-លោកវរៈសេនីយ៍ឯក ស៊ុម ឈាន់
១៣-លោកវរៈសេនីយ៍ឯក អេង ហុង
១៤-លោកវរៈសេនីយ៍ឯក ហេង ពេជ្យ
១៥-លោកវរៈសេនីយ៍ឯក យ៉ាល់ សុឃុន
១៦-លោកវរសេនីយ៍ទោ សុវណ្ណ គីមហាក់
១៧-លោកវរៈសេនីយ៍ទោ ម៉ៅ ចន្ទ្រះ
១៨-លោកវរៈសេនីយ៍ទោ ខៀវ សំណាង
១៩-លោកវរៈសេនីយ៍ទោ ហ៊ុន សុធី
២០-លោកវរសេនីយ៍ទោ ហ៊ូ ទាវ៉ន់នី
២១-លោកវរសេនីយ៍ទោ ញៀម ណារត្ន
២២-លោកវរសេនីយ៍ទោ ជាញ់ អេងប៊ុនចាន់
២៣-លោកវរៈសេនីយ៍ទោ ហ៊ឹង ចន្ធី
២៤-លោកវរៈសេនីយ៍ទោ ហែម សំបូរ
២៥-លោកវរសេនីយ៍ត្រី អ៊ឹម អេឡា

ឃ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-លោកឧត្តមសេនីយ៍ត្រី ឌឹម វ៉ា
២-លោកវរៈសេនីយ៍ឯក សំ ធីរៈ
៣-លោកស្រីវរសេនីយ៍ឯក លឹម សុវណ្ណា
៤-លោកវរសេនីយ៍ទោ អ៊ុង សុភី
៥-លោកវរសេនីយ៍ត្រី យក់ សុជាត
៦-លោកវរសេនីយ៍ត្រី ពេជ្រ សារឹន
៧-លោកវរសេនីយ៍ត្រី តុំ រីណា
១០-លោកវរសេនីយ៍ត្រី អ៊ុ សុបុណ្ណា
១១-លោកវរសេនីយ៍ត្រី ជា ចិន្តា
១២-លោកវរៈសេនីយ៍ត្រី តាំង ជុងប៉ី
១៣-លោកអនុសេនីយ៍ទោ ឡុង ចាន់រ៉ា
១៤-លោកអនុសេនីយ៍ត្រី យ៉េន ទាសនា
១៥-លោកអនុសេនីយ៍ត្រី ទ៉េន ខុយ
១៦-លោកអនុសេនីយ៍ត្រី ទែ ចន្ទតារា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៨-លោកវរសេនីយ៍ត្រី ឌិត ចិន
៩-លោកវរសេនីយ៍ត្រី អ៊ុម ធីរៈ
១៧-លោក ម៉ិល សុផល

ខ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម មុំ ក្រាត
២-លោកឧត្តមសេនីយ៍ទោ ស៊ុន សុផល
៣- លោកឧត្តមសេនីយ៍ទោ ម៉ម ស្រ៊ុមចន្ទ្រា
៤-លោកឧត្តមសេនីយ៍ទោ គីម សារេន

ច. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកជំទាវ ឃុន ផែនី
២-លោកជំទាវ អេង ចិន្តណា
៣-លោកជំទាវ ចិន ដារា
៤-លោកវរៈសេនីយ៍ឯក គុច សសុផាត
៥-លោកវរៈសេនីយ៍ឯក ខួន ស្រេង
៦-លោកវរសេនីយ៍ឯក ណុប ទី
៧-លោកវរៈសេនីយ៍ទោ ឈុន សំបូរត្ន
៨- លោកវរៈសេនីយ៍ទោ ម៉ៅ សុគ័ក្រ
៩- លោកវរៈសេនីយ៍ទោ ជម រ៉ាដា
១០- លោកវរៈសេនីយ៍ទោ ស៊ាន សុផាត
១១-លោកវរៈសេនីយ៍ទោ នួច សុតី
១២-លោកវរៈសេនីយ៍ទោ នៃ ហេង
១៣-លោកវរៈសេនីយ៍ត្រី ជាម ជម្ពូរ័ត្ន
១៤-លោកវរៈសេនីយ៍ត្រី នុត សារិទ្ធិ
១៥-លោកអនុសេនីយ៍ឯក ប៊ូ សំអាត
១៦-លោកអនុសេនីយ៍ឯក ស៊ុខ សុខហ៊ាប
១៧-លោកអនុសេនីយ៍ឯក ស៊ុន សុផាន់
១៨-លោកអនុសេនីយ៍ឯក គុត សុខសួ
១៩-លោកអនុសេនីយ៍ឯក ស៊ុច ចាសនា
២០-លោក ឈឿង ជ
២១-លោក YOSHIKAWA YASUTAKE
២២-លោកស្រី វេជ្ជបណ្ឌិត ម៉ី ចន្ទ្រារ៉េត
២៣-លោក ឃុន តេនា
២៤-លោក ផាត តារះ
២៥-លោក សុខ ឈិនផាត
២៦-លោក អ៊ូ ឡុងឌី
២៧-លោក ឡេង ចន្ថន
២៨-លោក សុះ ស្លេះ
២៩-លោក ពិរ ចន្ទ្រះ

ឆ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោកវរសេនីយ៍ទោ ឌិត ស៊ីណា
២-លោកវរសេនីយ៍ត្រី ឌិន ប្រសិទ្ធិ
៣-លោកអនុសេនីយ៍ឯក ខួន សុខហួត
៤-លោកអនុសេនីយ៍ឯក សេ គីមឈាង
៥-លោកស្រីអនុសេនីយ៍ឯក ខួន សុខខេង
៦-កញ្ញាអនុសេនីយ៍ឯក ខួន សុខឡើច

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១៣០១.០០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ០៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ លោកស្រី អស់លោក និងសប្បុរសជនបានខិតខំយកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ចរបស់ខ្លួនរួមចំណែកកសាង និងអភិវឌ្ឍន៍គ្រប់វិស័យក្នុងខេត្តបាត់ដំបង

នូវ

ក.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម ស៊ឹម សុខវឌ្ឍី
២-ឯកឧត្តម ម៉ូវ ផល្លា
៣-លោកជំទាវ ឈី ចាន់នីណា
៤-ឯកឧត្តម ម៉ៃ សុខ
៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក សោម សុភាញ់
៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក សួត ធី
៧-លោកឧត្តមសេនីយ៍ទោ អ៊ឹម ពុទ្ធនិមិត
៨-លោកឧត្តមសេនីយ៍ទោ សេង ចន្ថុះ
៩-លោកឧត្តមសេនីយ៍ត្រី ម៉ុក ចន្ថា
១០-លោកវរសេនីយ៍ឯក ឡូន ស្រេង
១១-លោកស្រី ទីស្សេ ចំប៊ូតី
១២-លោកវរសេនីយ៍ទោ ម៉ុង ឈី
១៣-លោកវរសេនីយ៍ទោ ម៉ុង ចន្ធី
១៤-លោក សុ សុផាន់ណា

ខ.គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេនា ចំពោះ :

១-លោក កៅ ទាវីណា
២-លោក ហៀក ធុន្ធី
៣-លោក ខៀវ មីណា
៤-លោក ឈឹម ប៊ុនឡេង
៥-លោកស្រីអ៊ិត ស៊ីថន
៦-ព្រះគ្រូចៅអធិការ ចិន ចេត
៧-លោក ឈឹម សុធា

គ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-លោក សុខ ហ៊ី
២-លោក គូ ឈិ
៣-លោក ឡេង សុផាន
៤-លោក ខេង បុត្តិន
៥-លោក ខៀត សុខ
៦-លោក គូ សុផល
៧-លោក ចូ ឆាយ
៨-លោក អ៊ុ ទិដ្ឋា
៩-លោក ឡេង សុភាព
១០-លោក សុះ ឫទ្ធី
១១-លោក ម៉ៅ សុខវណ្ណារិទ្ធ

ឃ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-លោក សោម សាមុត
២-លោក ស៊ាង សាមាន
៣-លោក គេង គឹម
៤-លោក ឈី ការីម
៥-លោក សោម ជាទីន
៦-លោកអនុសេនីយ៍ឯក ឡូន សុខឃួន
៧-លោកអនុសេនីយ៍ឯក អង់ គឹមឈាង
៨-លោកស្រីអនុសេនីយ៍ឯក ឡូន សុខមេង
៩-កញ្ញាអនុសេនីយ៍ឯក ឡូន សុខឃ្លិច
១០-លោក សាន សីហៈ
១១-លោក សែម ទិតិក

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៩.១៣០១.០០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

លេខ: ០៤ ច.ល
បានឃើញថាត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ដូច

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

ចំពោះ

លោកឧកញ៉ា **សា ឈាង**

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ
ព្រះពុទ្ធសាសនា សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងចូលរួមចំណែក ជួយសាងសង់អគារកាកបាទក្រហមខេត្ត
នៅខេត្តព្រៃវែង ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស. ១៣០១.០០៤

លេខ: ១៥ ច.ល
[illegible] ចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៣
[illegible] រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០០៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យលព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០១ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល៖

ល.រ	គោត្តនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	សៀង សុខយុនឺ	ប	ក.២.៧	ក.១.៦

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានឃើញ [illegible]
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

៧២៦.១៣០១.០០៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៣

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជក្រឹត្យ

ត្រាស់បង្គាប់

មាត្រា ១: ដំឡើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្ដមសេនីយ៍ទោ** ជូនលោកឧត្ដមសេនីយ៍ត្រី **ឆាំង ឡាច** អត្តលេខ ០៣១៦ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

មាត្រា ២: សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៧ រក. ១៣០១-០១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៣

លេខៈ ១៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០២រូប មានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជួយឧបត្ថម្ភសំភារៈ ថវិកា និងជួយហ្វឹកហ្វឺនដល់នាយទាហានបញ្ជាការដ្ឋានអង្គរក្សលើជំនាញប្រើប្រាស់និងជួសជុលអាវុធ BM21 រថក្រោះ-រថពាសដែក កន្លងមក

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

១-ឧត្តមសេនីយ៍ទោ NGUYEN PHUONG NAM

២-ឧត្តមសេនីយ៍ត្រី NGUYEN HOANG THUY

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣រស. ១៣០១. ០១១

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៣

លេខៈ ១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/ ០១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង សមិទ្ធផលនានា នៅវត្តសិរីមង្គលសុទ្ធារាម ស្ថិតនៅក្នុងសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១-ព្រះគ្រូបឋមសីមាភាសី ឌុក ចំរើន
២-លោក អ៊ុង ម៉េងសុង
៣-ឧកញ៉ា អ៊ុង ម៉េងជី
៤-លោក សំ ហ៊ីសេង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-លោក ចៅ ម៉េងជួន
២-លោក ញឹម សុខណាង
៣-លោក អ៊ុង គីសេង
៤-លោកស្រី អ៊ុង គិចហ៊ួរ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារជ. ១៣០១.០១៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣

លេខ ១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

កងកំលាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ១២ រូប មានស្នាដៃល្អ ក្នុងការជួយកសាង
អាគារដាក់គ្រឿងបំពាក់ធុនធ្ងន់ ចំនួន ០៣ អាគារ នៅទីបញ្ជាការដ្ឋានអង្គរក្ស

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍:**

១-	ឧត្តមសេនីយ៍ឯក	**ស៊ី ហ៊ូហ៊ុយ**	៧-	លោកជំទាវ	**គង់ មាលា**
២-	ឧត្តមសេនីយ៍ទោ	**នួន សាធុន**	៨-	លោកស្រី	**គង់ ឆាវី**
៣-	ឧត្តមសេនីយ៍ទោ	**ម៉ែន សារ៉ាត់**	៩-	លោក	**ម៉ឹង យូឡេង**
៤-	ឧត្តមសេនីយ៍ទោ	**នន្ទ និន**	១០-	លោក	**សុខ ថៃ**
៥-	ឧត្តមសេនីយ៍ត្រី	**សេង គីលីន**	១១-	លោក	**ទ្រី សេងអាន**
៦-	វរសេនីយ៍ឯក	**ចូ តុំ**			

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេនា:**

- វរសេនីយ៍ឯក **អ៊ិន ឡេង**

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៧៩៤-១៣០១.០១៧

លេខៈ ១០ ប.ល
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ...១ ឆ្នាំ២០១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សាចិន ចំនួន ០៤ រូប មានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ ព្រមទាំងបានជួយបង្ហាត់បង្រៀន ដល់នាយទាហាន វិទ្យាស្ថានទ័ពជើងគោក អគ្គបញ្ជាការដ្ឋាន

នូវ

ក.គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ :

-វរសេនីយ៍ឯកពិសេស **ម៉ាន់ សុង ហ៊ឺ** (Senior Colonel Man Zhong He)

ខ.គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា:

១-វរសេនីយ៍ឯកពិសេស **ជូ ដូ ឡុង** (Senior Colonel Zhou Duo Long)
២-វរសេនីយ៍ឯកពិសេស **សុង ចាង ស៊ុន** (Senior Colonel Song Chang Shun)
៣-វរសេនីយ៍ឯក **ហ៊ឺ ជូ ជុន** (Colonel He Zhou Jun)

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣០១.០១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាល និងនាយនគរបាលជាតិជាន់ខ្ពស់ចំនួន ១០៧ រូប ដែលបានខិតខំប្រឹងប្រែង បំពេញភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ។

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៖

១-លោកឧត្តមសេនីយ៍ទោ	កុន	សុផល	អត្តលេខ ៥៤៦៧៦
២-លោកឧត្តមសេនីយ៍ទោ	គួច	ប៊ុនលាត	អត្តលេខ ០៦០៨

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៖

១-លោកឧត្តមសេនីយ៍ទោ	សុន	ខ្សៀ	អត្តលេខ ០៥៦៧
២-លោកឧត្តមសេនីយ៍ទោ	អ៊ុន	ចន្ថា	អត្តលេខ ២០៤១៣
៣-លោកឧត្តមសេនីយ៍ទោ	ពេជ្រ	ពិសិដ្ឋ	អត្តលេខ ៤៣៤៥៥
៤-លោកឧត្តមសេនីយ៍ត្រី	ឃឹម	សុវណ្ណារុធ	អត្តលេខ ០៩៥៥
៥-លោកឧត្តមសេនីយ៍ត្រី	ធឹង	បុត្រ	អត្តលេខ ៥៥១៥៤
៦-លោកឧត្តមសេនីយ៍ត្រី	អ៊ុំ	សំអូន	អត្តលេខ ០១២៤៩
៧-លោកឧត្តមសេនីយ៍ត្រី	ប្រាក់	ប៉ា	អត្តលេខ ០៨០៤
៨-លោកឧត្តមសេនីយ៍ត្រី	ប៉ែន	ចាន់ថុល	អត្តលេខ ០៨១៨

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង

៩-លោកឧត្តមសេនីយ៍ត្រី	អ៊ុយ	សារី	អត្តលេខ ០៩៨០
១០-លោកឧត្តមសេនីយ៍ត្រី	លៀង	ភារម្យ	អត្តលេខ ៥៤៧០៨
១១-លោកវរសេនីយ៍ឯក	មុំ	ណារ៉ែន	អត្តលេខ ៥៦៥០៨

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ៖

១-លោកស្រីឧត្តមសេនីយ៍ទោ	ថន	សុវណ្ណចំន្ទខេមា	អត្តលេខ ៥៤៥៦៣
២-លោកឧត្តមសេនីយ៍ត្រី	អ៊ឹម	ពុធទិរា	អត្តលេខ ៦២២៦៥
៣-លោកឧត្តមសេនីយ៍ត្រី	កែវ	ឡាជា	អត្តលេខ ០៨០៥
៤-លោកឧត្តមសេនីយ៍ត្រី	មុត	ម៉ៅ	អត្តលេខ ០៩៦៣
៥-លោកឧត្តមសេនីយ៍ត្រី	ជា	យឿន	អត្តលេខ ០៩១៥
៦-លោកឧត្តមសេនីយ៍ត្រី	ឆយ	ឈឿង	អត្តលេខ ០៨០៧
៧-លោកឧត្តមសេនីយ៍ត្រី	ម៉ែន	រតនា	អត្តលេខ ០៨១១
៨-លោកឧត្តមសេនីយ៍ត្រី	អោគ	សាម៉ុន	អត្តលេខ ០៣៧៦៨
៩-លោកឧត្តមសេនីយ៍ត្រី	នួន	វិឡាសក់	អត្តលេខ ០៨៥៧
១០-លោកវរសេនីយ៍ឯក	សេង	សុកក្តី	អត្តលេខ ០១៨០៨
១១-លោកវរសេនីយ៍ឯក	ផន	សុភា	អត្តលេខ ០៩៩០
១២-លោកវរសេនីយ៍ឯក	ព្រិល	វ៉ាន់ថន	អត្តលេខ ០៤៩០២
១៣-លោកវរសេនីយ៍ឯក	រិញ	ឡា	អត្តលេខ ០៥៨៤៥
១៤-លោកវរសេនីយ៍ឯក	ឃុន	រិទ្ធី	អត្តលេខ ០៥៨២៣
១៥-លោកវរសេនីយ៍ឯក	ឈឹម	សុផល	អត្តលេខ ២០៤៥៧
១៦-លោកវរសេនីយ៍ឯក	ខែក	ចាន់វណ្ណៈ	អត្តលេខ ០៤១១៦
១៧-លោកវរសេនីយ៍ឯក	ង៉ែត	ណាន	អត្តលេខ ០៥៨៨១
១៨-លោកវរសេនីយ៍ឯក	ថន	សុវណ្ណចំន្ទសីម៉ា	អត្តលេខ ៥៤០៤៤
១៩-លោកវរសេនីយ៍ឯក	ទុំ	គង្គា	អត្តលេខ ២០៨៧៤
២០-លោកវរសេនីយ៍ឯក	ជា	អៀន	អត្តលេខ ០១៤៤៨
២១-លោកស្រីវរសេនីយ៍ឯក	លៀង	វត្តី	អត្តលេខ ៥៦៩៦៩
២២-លោកវរសេនីយ៍ឯក	ស៊ុម	សុជាតិ	អត្តលេខ ៦១៩៩៨
២៣-លោកវរសេនីយ៍ឯក	កែន	សុធន់	អត្តលេខ ៥៣៧៩៥

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា៖

១-លោកឧត្តមសេនីយ៍ត្រី	ពៅ	វុទ្ធី	អត្តលេខ ០៥៩៤១
២-លោកស្រីវរសេនីយ៍ឯក	យន	ស្រីនាង	អត្តលេខ ៥៨០៥៧

៣-លោកវរសេនីយ៍ឯក	ហៀ	រិទ្ធី	អត្តលេខ ៦៧០១០
៤-លោកវរសេនីយ៍ឯក	ហង្ស	សោភ័ណ្ឌ	អត្តលេខ ២០៤៨០
៥-លោកវរសេនីយ៍ឯក	ប៊ុន	សុសិក្ខា	អត្តលេខ ៦៦៩៦៨
៦-លោកវរសេនីយ៍ឯក	សំ	អឿន	អត្តលេខ ២០៤៤៣
៧-លោកវរសេនីយ៍ឯក	លី	សារ័ន្ត	អត្តលេខ ៥៥៣៩៥
៨-លោកស្រីវរសេនីយ៍ទោ	ជា	ស៊ិន	អត្តលេខ ២០៤៧៨
៩-លោកវរសេនីយ៍ទោ	សូ	សាភ៉ត	អត្តលេខ ០៧២៥៤
១០-លោកវរសេនីយ៍ទោ	ហែម	សំអុន	អត្តលេខ ០៤៩០៥
១១-លោកវរសេនីយ៍ទោ	ឯម	សារិន	អត្តលេខ ០៧១៧៦
១២-លោកវរសេនីយ៍ទោ	កែវ	ស្មើ	អត្តលេខ ០៤៩៤៦
១៣-លោកវរសេនីយ៍ទោ	ស៊ិន	ប៊ុនឡា	អត្តលេខ ៥៥១៥៩
១៤-លោកវរសេនីយ៍ទោ	អ៊ុំ	សុភា	អត្តលេខ ៥៥១៦៧
១៥-លោកវរសេនីយ៍ទោ	ឈិន	ទី	អត្តលេខ ៤៤៤៤០
១៦-លោកវរសេនីយ៍ទោ	ឈឹម	ឋាណាវណ្ណ	អត្តលេខ ០៤៩០១
១៧-លោកវរសេនីយ៍ទោ	លឹម	ហួរ	អត្តលេខ ១៧៤៥៦
១៨-លោកវរសេនីយ៍ទោ	ឡេង	បូរាណ	អត្តលេខ ០៦០២៤
១៩-លោកវរសេនីយ៍ទោ	ពេជ	ឃឹម	អត្តលេខ ៥៦២៧៨
២០-លោកវរសេនីយ៍ទោ	បេង	បញ្ញរិទ្ធ	អត្តលេខ ០៥៨៣៤
២១-លោកវរសេនីយ៍ទោ	ឡុង	ម៉ូនីកា	អត្តលេខ ៥៥៦១០
២២-លោកវរសេនីយ៍ទោ	ពាង	ចាន់ថន	អត្តលេខ ៣១៤១៥
២៣-លោកវរសេនីយ៍ទោ	ស៊ីវ	ឈាន់	អត្តលេខ ៥៥១៤៩
២៤-លោកវរសេនីយ៍ទោ	ស្រ៊ិន	សំឫទ្ធី	អត្តលេខ ៥៩៧៤៧
២៥-លោកវរសេនីយ៍ទោ	មាស	ពេញ	អត្តលេខ ១៣១២៣
២៦-លោកវរសេនីយ៍ទោ	ជា	សំអុល	អត្តលេខ ២០៤២១
២៧-លោកវរសេនីយ៍ទោ	ចាន់	សុភា	អត្តលេខ ០៥៨៨៤
២៨-លោកវរសេនីយ៍ទោ	នុត	សុខលី	អត្តលេខ ០៤៩០០
២៩-លោកវរសេនីយ៍ទោ	ជុំប	ស៊ីនួន	អត្តលេខ ២០៤៣៧
៣០-លោកវរសេនីយ៍ទោ	យ៉ែម	សារ៉ាវុធ	អត្តលេខ ២០៤៧២
៣១-លោកវរសេនីយ៍ទោ	ទូច	សុភា	អត្តលេខ ៦៨១៩៥

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៖

១-លោកស្រីវរសេនីយ៍ទោ	កុន	សុភារី	អត្តលេខ ៥៨០៤៤
២-លោកវរសេនីយ៍ទោ	លន	ឈឿង	អត្តលេខ ០៥៥៤៨
៣-លោកវរសេនីយ៍ទោ	ហុង	រតនៈ	អត្តលេខ ៥៧៩៩៦
៤-លោកវរសេនីយ៍ទោ	ឡេង	គឹមហុង	អត្តលេខ ៥៧៣១៧
៥-លោកវរសេនីយ៍ទោ	ស	ម៉ូលីនីន	អត្តលេខ ៥៤៩៧៨
៦-លោកស្រីវរសេនីយ៍ទោ	ស៊ាង	លាងហ៊ិន់	អត្តលេខ ៣១៤៣០
៧-លោកវរសេនីយ៍ទោ	ជឹម	រ៉ិន	អត្តលេខ ៣១៤៤២
៨-លោកស្រីវរសេនីយ៍ទោ	ស្វាយ	ស៊ីថា	អត្តលេខ ៥៨០៤៣
៩-លោកវរសេនីយ៍ទោ	ឡុង	ឆេក្ង	អត្តលេខ ៥៨០៤៥
១០-លោកវរសេនីយ៍ទោ	គង់	វីរៈ	អត្តលេខ ៥៥៣៨០
១១-លោកវរសេនីយ៍ទោ	សេក	ពិសិដ្ឋ	អត្តលេខ ៣១៤២១
១២-លោកវរសេនីយ៍ទោ	ហុង	ណារ៉ុង	អត្តលេខ ៦៦៩៥៤
១៣-លោកវរសេនីយ៍ទោ	ទឹម	វ៉ាំរុធ	អត្តលេខ ០៥៨៧៦
១៤-លោកវរសេនីយ៍ទោ	ឈី	ជាង	អត្តលេខ ៦២៤៨៤
១៥-លោកវរសេនីយ៍ទោ	នួន	ប៊ុន្នី	អត្តលេខ ៦២៥៣១
១៦-លោកវរសេនីយ៍ទោ	ទឹម	វន្ថា	អត្តលេខ ៥៤៦៧៧
១៧-លោកវរសេនីយ៍ទោ	ព្រំ	ជី	អត្តលេខ ២០៤៣០
១៨-លោកវរសេនីយ៍ទោ	ប្រាក់	ប៊ុនថា	អត្តលេខ ៥៦២៥២
១៩-លោកវរសេនីយ៍ត្រី	ឯក	សៅដា	អត្តលេខ ៥៤៦៩៨
២០-លោកវរសេនីយ៍ត្រី	ធូ	សេងអ៊ាន់	អត្តលេខ ៣២២២៧
២១-លោកវរសេនីយ៍ត្រី	ក្រូច	សេដ្ឋ	អត្តលេខ ៥៧៩១២
២២-លោកវរសេនីយ៍ត្រី	ឃួន	ដារ៉ា	អត្តលេខ ០៩៣៤២
២៣-លោកវរសេនីយ៍ត្រី	នេត្រ	ចំណាន	អត្តលេខ ២០៤៥០
២៤-លោកវរសេនីយ៍ត្រី	មុយ	គឹមហេង	អត្តលេខ ៦២០០០
២៥-លោកស្រីវរសេនីយ៍ត្រី	សម	ដារ៉ា	អត្តលេខ ៣១៤១១
២៦-លោកវរសេនីយ៍ត្រី	រស់	សុគន្ធី	អត្តលេខ ២០៤៧៣
២៧-លោកវរសេនីយ៍ត្រី	អ៊ុក	ស៊ីថារៈ	អត្តលេខ ២០៤២៨
២៨-លោកវរសេនីយ៍ត្រី	ម៉ា	ផាត	អត្តលេខ ១៦៩៦៥
២៩-លោកវរសេនីយ៍ត្រី	ធូក	ឡា	អត្តលេខ ០៥៦២១

៣០-លោកវរសេនីយ៍ត្រី	ឈន់	សុខែម	អត្តលេខ ៦៦៩៥៦
៣១-លោកវរសេនីយ៍ត្រី	សាន	សារឿន	អត្តលេខ ០៧០២៦
៣២-លោកវរសេនីយ៍ត្រី	ធន	សុធារ័ត្ន	អត្តលេខ ៦៤២១០
៣៣-លោកវរសេនីយ៍ត្រី	ជឹម	គឹមថេង	អត្តលេខ ៣១៣៩៣
៣៤-លោកវរសេនីយ៍ត្រី	សំ	យ៉ារ៉ាន់	អត្តលេខ ៣១៤២៤
៣៥-លោកវរសេនីយ៍ត្រី	ហ៊ុយ	ច័ន្ទពិសិដ្ឋ	អត្តលេខ ៦៦០០៩
៣៦-លោកវរសេនីយ៍ត្រី	ហួង	ស៊ុនហ៊ីន	អត្តលេខ ៥៤៣៩៨
៣៧-លោកវរសេនីយ៍ត្រី	មិន	សុគន្ធវិបុល	អត្តលេខ ៥៣៥៣៧
៣៨-លោកអនុសេនីយ៍ឯក	ជា	ដែន	អត្តលេខ ៥៧៣៧៣
៣៩-លោកអនុសេនីយ៍ឯក	ព្រហ្ម	មេសាឡុងឌី	អត្តលេខ ៦៤២១៣
៤០-លោកអនុសេនីយ៍ឯក	សូ	សុវណ្ណារិទ្ធ	អត្តលេខ ៦៤២២១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នសរកត.១៣០១.០១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៣

លេខៈ ០៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៣
[illegible]ជាតិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០៣ នាក់ បានយកអស់កំលាំងកាយចិត្តខិតខំបំពេញភារកិច្ចបំរើជាតិមាតុភូមិ និងបានរួមចំណែកយ៉ាងសកម្មក្នុងការជួយកសាង និងអភិវឌ្ឍន៍លើគ្រប់វិស័យក្នុង ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ :

-លោកឧត្តមសេនីយ៍ឯក ជឹម សុផា អត្តលេខ ០៦០៧

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេនា :

១-លោកឧត្តមសេនីយ៍ត្រី ច័ន្ទ សុខា អត្តលេខ ០១៨០៩

២-លោកឧត្តមសេនីយ៍ត្រី អ៊ុំ ប៊ុនថន អត្តលេខ ០១២៨០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១៣០១.០១៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

លេខ ១៦ ប.ល
បានឃើញ និងចម្លងត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- ឯកឧត្តម **ស្វាង ម៉េងឡុង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

២- លោកជំទាវ **ឃៀវ ស្រីម៉ន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

៣- ឯកឧត្តម **ឈុំ គុនលី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការស: ១៣០១.០១៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣

លេខ: ០១ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៣
[illegible] រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងមន្ត្រីរាជការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ :

១. ឯកឧត្តម **ស៊ុំ សន្និសិទ្ធ**	ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **ខង្ស ប៊ុនឥន្ទ្រាខុង**	ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៣. ឯកឧត្តម **ហេង សួរ**	ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៤. ឯកឧត្តម **ជាម ជាវុធ** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៥. ឯកឧត្តម **អ៊ុំ សីហា** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៦. ឯកឧត្តម **ហ៊ុច សុវណ្ណ** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៧. ឯកឧត្តម **គុណា ញ៉ឹម** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៨. ឯកឧត្តម **ឈើម យីសៀង** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៩. ឯកឧត្តម **អ៊ុយ សារិន** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១០. ឯកឧត្តម **ឡៅ និពូសីហា** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

១១. ឯកឧត្តម **ទី ឡាយមិថុនា** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១២. ឯកឧត្តម **ម៉ិញ ខានសុវណ្ណអានិច្ចាសីលា** ជាជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៣. ឯកឧត្តម **ស៊ីសុវត្ថិ ជួចចំនួនោ** ជាជំនួយការអនុប្រធានប្រចាំការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៤. ឯកឧត្តម **ខាន់ ចន្ទ្រះ** ជាជំនួយការអនុប្រធានប្រចាំការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៥. ឯកឧត្តម **អេង ឌួច** ជាជំនួយការឯកឧត្តម **វង្សី វិស្សុត** អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៦. ឯកឧត្តម **ម៉ុច សុវណ្ណឌី** ជាជំនួយការឯកឧត្តម **ទួន ថាវរៈ** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE
LE MINISTÈRE ROYAL

១៧. ឯកឧត្តម **នាយ គេនះ** ជាជំនួយការឯកឧត្តម **រស់ សីលវ៉ា** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០១១៣.០១៨

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣

លេខ: ១៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសបញ្ជាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ហារាស៊ីកូវ៉ា អាលីហ្សា** (HARASIKOVA ALISA) ជនជាតិរុស្ស៊ី សញ្ជាតិអ៊ុយបេគីស្ថាន កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៨៣ នៅតំបន់តាស្កេន ប្រទេសអ៊ុយបេគីស្ថាន ដោយប្តូរឈ្មោះជា **សុខ អាលីហ្សា** (SOK ALISA)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

០២៧០១.០២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

លេខ: ១៦៥ ប.ល
[illegible]ចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៣
[illegible]លេខាធិការ[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **មីខៃឡូវ ស្តានីស្លាវ** (MIKHAILOV STANISLAV) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ១៩៨៣ នៅទីក្រុងឆេលយ៉ាប៊ីន សហព័ន្ធរុស្ស៊ី ដោយប្តូរឈ្មោះជា **រ៉ូស ស្ទីវិន** (ROSS STIVEN)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រសា.១៣០១.០៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

ប.ល

រាជធានីភ្នំពេញ ... ឆ្នាំ២០១៣

... រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **រោមស៊ីន មីខាអ៊ីល** (RYUMSHIN MIKHAIL) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៧៥ នៅទីក្រុងអាល់ហ្គាបេជ សហព័ន្ធរុស្ស៊ី។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ២៣ ប.ល

បានចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៣

[illegible] រដ្ឋាភិបាល

[illegible] សុខា

៣៣៥. ១៣០១. ០២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អូ មូនតៃ** (OH MOON TAI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៥៥ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **អូរ គីមសាន្ត** (OH KIMSAN) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

ព.រ.ក.១៣០១.០៧៧

លេខ ៤៧ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា នាយ នាយរងនគរបាលជាតិ និងសប្បុរសជនដែលបានខិតខំយកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ចរបស់ខ្លួន រួមចំណែកកសាង និងអភិវឌ្ឍគ្រប់វិស័យក្នុងឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង

នូវ

ក. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឧកញ៉ា **ហុង នាយ**
២-Mr. YAP SINGHOCK
៣-លោកឧត្តមសេនីយ៍ទោ **ខួន ញ៉ឹក់**
៤- លោកឧត្តមសេនីយ៍ត្រី **ឆាំង ណារ៉េន**
៥- លោកឧត្តមសេនីយ៍ត្រី **អ៊ី សុខឃី**
៦- លោកឧត្តមសេនីយ៍ត្រី **សែន សម្បត្តិ**
៧- លោកវរសេនីយ៍ឯក **យូ សារ៉ុ**

ខ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកវរៈសេនីយ៍ត្រី **នេង ឡុង**
២-លោកអនុសេនីយ៍ឯក **អ៊ី សុធី**
៣- លោកអនុសេនីយ៍ទោ **ម៉េង សារឿន**
៤- លោកអនុសេនីយ៍ទោ **ម៉ម ចាន់រ៉ាវុធ្ឋ**
៥- លោកអនុសេនីយ៍ទោ **ជាស ថៃ**
៦- លោកព្រិន្ទបាលឯក **សុខ ច័ន្ទតុលា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣០១.០៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៤០ ច.ល
[illegible]ចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ [illegible] ឆ្នាំ២០១៣
[illegible]រដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោកជាមន្ត្រីរាជការ និងសប្បុរសជនបានខិតខំ
យកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ចរបស់ខ្លួនរួមចំណែកកសាង និងអភិវឌ្ឍន៍គ្រប់វិស័យក្នុងខេត្តបាត់ដំបង

នូវ

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានីព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ចៅ សុធី
២-ឯកឧត្តម ចៅ គៀង
៣-ឯកឧត្តម ង៉ែង ច័ន្ទថា
៤-ឯកឧត្តម មួង សុធា
៥-ឯកឧត្តម ឌី សុខុន
៦-លោក ម៉ែន ចំឡងរិទ្ធិ
៧-លោក សៀម ប៊ុនរិទ្ធិ

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឧកញ៉ា ខេន សុភា
២-លោក អ៊ឹង វ៉ៃហេង
៣-លោក សួង ប៊ុនគង់
៤-លោក សុខ ចន្ទអឿន
៥-លោក ឌី ឈៀង
៦-ឧកញ៉ា យូ សារ៉ុ
៧-លោក លីម វ៉ាសុឡូ
៨-លោក គ្រី ចំរើន
៩-លោក គី សើ
១០-លោក ខា សង្ហាសេរីវឌ្ឍន៍
១១-លោក ចន្ទ្រា សុផល

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកស្រី សៀងឯម ឆនីម
២-លោក ប៊ិន ផុំ
៣-លោក ម៉ាន់ ផុល
៤-លោក សុខ ហ្វួត
៥-លោក គង់ ហ៊ាន
៦-លោក យ៉ាន់ បូវ៉ៃ
៧-លោក គួច ឈុនសេរីវុឌ្ឍ
៨-លោក អ៊ុត ខ្លឹង
៩-លោកស្រី ឆិត លីនដា
១០-លោក ម៉ី ហ៊ុនហួ
១១-លោក សៀងឯម សត្យា
១២-លោកស្រី ឌី ម៉ារ៉ានី
១៣-លោក លី ជូរហៀង
១៤-លោក ជួង សុភា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ទស. ១៣០១. ០៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

លេខ: ... ច.ល
សេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣
...ទីស្តីការគណៈរដ្ឋមន្ត្រី...
... សុខា

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីទំហំ ៥២០,១៧១៧ ហិកតា ស្រុកបរកែវ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន ជា ច័ន្ទរិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១០៧ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១២ របក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៥២០,១៧១៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាច័ន្ទរិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ៥០០,០៥៩៦ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២០,១១២១ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិគ្រៀង ឃុំកិះចុង ស្រុកបរកែវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

